## ក្រុមប្រឹក្សាសិក្សាធិការ

Bobbie Smith, ប្រធាន

Mary Stanton, អនុប្រធាន

Suja Lowenthal, សមាជិក

Jim Choura, សមាជិក

Jon Meyer, សមាជិក

## អគ្គនាយកសាលារៀន

Christopher Steinhauser



បោះពុម្ពដោយ
ការិយាល័យកម្មវិធីអប់រំ ការបង្ហាត់បង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
Christine Dominguez
អនុអគ្គនាយក

ក្រសួងសិក្សាធិការតំបន់ឡុងប៊ិច
1515 Hughes Way
Long Beach, Ca. 90810

(562) 997-8000

long beach unified school district

ការធ្វើទំនាក់ទំនង....

# ថ្នាក់ទី២

## កិច្ចការដែលមាតាបិតាអាចជួយបាននៅផ្ទះ

បេសកកម្មរបស់ក្រសួងសិក្សាធិការធីស្ទ្រិកឡុងប៊ិច គឺដើម្បីធានាផ្តល់នូវជ័យជំនះក្នុងការសិក្សាដល់សិស្សគ្រប់រូប ដោយសេចក្តីសង្ឃឹមប្រាថ្នាដ៏ខ្ពង់ខ្ពស់ ការប្តេជ្ញាដើម្បីឧត្តមភាព ហើយនិងការផ្តល់កម្មវិធីសិក្សាដែលច្បាស់លាស់ ដើម្បីពង្រឹងបញ្ជាក់អះអាងលើសេចក្តីជំនឿរបស់សិស្សគ្រប់រូប ដែលគេអាចរៀនសូត្រឲ្យបានក្លាយជាអ្នកចេះទទួលខុសត្រូវ ហើយនិងក្លាយជាសមាជិកដែលមានផលប្រយោជន៏ក្នុងសង្គម។

**Second Grade**

## ទំព័រសម្រាប់កត់កំណត់ហេតុ

# អក្ខរានុក្រមនៃពាក្យ

## ខាងក្រោមនេះគឺជាពាក្យប្រើក្នុងការសិក្សាដែលលោកអ្នក អាចឮសួរកូន ឬ គ្រូបង្រៀនរបស់កូនលោកអ្នកនិយាយ

**Automaticity-** ការចេះដឹងភ្លាមៗដោយគ្មានបានគិតទុកជាមុន។

**Basic Facts-** ឈុតមួយពេញគ្រប់ក្នុងការគិតលេខ បូក ដក គុណ និងចែកដែលរៀនចេះចាំមាត់ស្ទាត់។

**Benchmark-** ការស្ទង់ចំណេះមួយដើម្បីប៉ាន់មើលកំរឹតចេះអានរបស់សិស្សទៅលើសៀវភៅដែលបានសរសេរប្រឌិតនិងសៀវភៅដែលយោលតាមព្រឹត្តិការណ៏ពិត។

**Comprehension-** ការយល់ដឹងនូវអ្វីៗដែលបានអាន។

**Content Standards-** ចំណេះដែលសិស្សត្រូវដឹងហើយអាចធ្វើបាននៅចុងកំរឹតថ្នាក់ នៅក្នុងមុខវិជ្ជានិមួយៗ។

**Decode-** និយាយប្រកបពាក្យហើយអានពាក្យនៅលើទំព័រសៀវភៅ។

**ELD-(English Language Development)** សិស្សដែលរៀនភាសាអង់គ្លេសដែលត្រូវការការបង្ហាត់បង្រៀនក្នុងការស្តាប់ និយាយ អាន ហើយនិងសរសេរដើម្បីឲ្យបានលូតលាស់ទៅដល់ភាពចេះភាសាអង់គ្លេសគ្រប់គ្រាន់។

**Formal Assessment-** ការស្រង់ប្រមូលពិន្ទុនិងលិទ្ធផលសិស្សដោយប្រើតែស្តបមាណីយប្ញទម្រង់ការណ៏នៅក្រោមស្ថានភាពដែលមានការត្រួតត្រាមើល។

**Genre-** ផ្នែកមួយដែលប្រើសម្រាប់ចាត់ជាជំពូកការសរសេរនិពន្ធ តាមធម្មតាដោយប្រភេទ របៀប ឬ មាតិការ (ឧ. រឿងព្រេង រឿងប្រឌិតយោលទៅតាមព្រឹត្តិការណ៏ពិត ជីវប្រវត្ត កំណាព្យជាដើម)។

**High Frequency Words-** ពាក្យដែលប្រើញឹកញាប់ជាងពាក្យដ៏ទៃនៅក្នុងការនិយាយឬសរសេរ។

**Interactive Writing-** សិស្សហើយនិងគ្រូបង្រៀនបង្កើតសារមួយហើយ “ផ្លាស់វេនគ្នាសរសេរ” នៅពេលសរសេរសារនោះនៅលើផ្ទាំងក្រដាសធំមួយ ហើយសិស្សផ្លាស់វេនគ្នាសរសេរអក្សរ ពាក្យហើយនិងដាក់វណ្ណយុត្ត។

**OEM-(Open Ended Math)-** ប្រភេទសំនួរម៉្យាងដែលប្រើសម្រាប់រុករកការយល់ដឹងរបស់សិស្សទៅលើមុខវិជ្ជាដើម្បីបង្កើតចម្លើយដោយសេរីជាជាងចម្លើយដែលត្រូវឆ្លើយតាមក្បួន។

**Performance Standards-** តើល្អប៉ុណ្ណាទៅដែលល្អល្មមនៅលើការស្ទង់ប៉ាន់មើលចំណេះអ្វីមួយឬការស្ទង់ប៉ាន់រួមដើម្បីបង្ហាញការចេះដឹងទៅលើចំណេះដែលសិស្សត្រូវដឹងហើយអាចធ្វើបាននៅចុងកំរឹតថ្នាក់ នៅក្នុងមុខវិជ្ជានិមួយៗ។

**Phonemic Awareness-** ការយល់ដឹងជាគោលៗអំពីសំឡេងពាក្យដែលចេញមកពីសំឡេងដែលឮសួរនិមួយៗ។ ការយកចិត្តទុកដាក់គឺសំដៅទៅលើការនិយាយស្តី មិនមែននៅពេលបញ្ចេញសំឡេងពាក្យពេលអាននោះទេ។

**Probable Indicator-** ការស្ទង់ប៉ាន់ Benchmark “ហាត់សាកមើល” ក្នុងការអាន ដើម្បីផែកមើលកំរឹតចេះអានរបស់សិស្សមុននិងធ្វើការស្ទង់ប៉ាន់ Benchmark យកជាផ្លូវការ។

**Prompt-** កិច្ចការសិស្សត្រូវសរសេរទៅតាមគោលការណ៏ណែនាំច្បាស់លាស់នៅក្នុងគោលប្រធានឬប្រភេទណាមួយ។

**Prior Knowledge-** ការចេះដឹងដែលកើតមកពីបទពិសោធន៏កន្លងមក។

**Retention-** ការសម្រេចចិត្តសម្រាប់ឲ្យសិស្សរៀនថ្នាក់កំរឹតដដែលយោលទៅតាមខ្នាតគំរូរបស់ក្រសួងអប់រំ។

**Rubric-** លំនាំសម្រាប់ស្ទង់មើលការលូតលាស់របស់សិស្សនៅក្នុងគ្រប់មុខវិជ្ជាទាំងអស់។

**SSR-(Sustained Silence Reading)** ការអានដោយខ្លួនឯងឲ្យបានពី២០-៣០នាទី ដែលជនរាល់គ្នានៅក្នុងថ្នាក់ឬសាលាផ្អាកធ្វើអ្វីៗដែលគេកំពុងធ្វើហើយចំណាយពេលអានសៀវភៅដែលគេជ្រើសរើសខ្លួនឯង។

ពាក្យប្រើ **Rubric** ដែលត្រូវដឹង:

**Advanced Proficient:** មួយឆ្នាំឡើងទៅលើសពីកំរឹតថ្នាក់

**Proficient:** នៅស្មើកំរឹតថ្នាក់ឬលើសជាងបន្តិច

**Partially Proficient:** នៅក្រោមកំរឹតថ្នាក់ (ពីកន្លះឆ្នាំទៅពីរឆ្នាំ)

**Not Proficient:** ពីរឆ្នាំឡើងទៅក្រោមកំរឹតថ្នាក់

# ទីបណ្ដាញ Website និងលេខទូរស័ព្ទ

ក្រសួងសិក្សាធិការតំបន់ឡុងប៊ិច Long Beach Unified School District:
(562) 997-8000 ឬ www.lbusd.k12.ca.us

បណ្ណាល័យធំ
(562) 570-7500 ឬ www.lbpl.org

ក្រសួងសិក្សាធិការប្រចាំរដ្ឋ California Department of Education:
www.cde.ca.gov

# សៀវភៅសម្រាប់ថ្នាក់ទី២

- Open Court Reading, SRA McGraw-Hill 2002
- Open Court Spelling & Vocabulary, SRA McGraw-Hill 2002
- Language Arts Handbook, SRA McGraw-Hill 2002
- Houghton Mifflin Mathematics, Houghton Mifflin 2002
- Adventures in Time and Space, Macmillan McGraw-Hill 1999
- Discovery Works, Houghton Mifflin 2000
- Portfolios, Barrett Kendall Publishing
- The Music Connection, Silver Burdett Ginn

## ប្រូក្រាមកុំព្យូទ័រសម្រាប់កូនលោកអ្នក
## Computer Software...

«Orchard for California»
«Destination Reading:  Course 2»
«Earobics Literacy: Step 2»
«Cornerstone Reading»

### ប្រូក្រាមសម្រាប់សរសេរ

«Kidspiration»

### ប្រូក្រាមសម្រាប់គណិតសាស្ត្រ

«Larson's Elementary»
«Math Blaster»

ទីបណ្ដាញ Website របស់ក្រសួងសិក្សាធិការឡុងប៊ិច LBUSD (ឯកសារយោងអំពីក្បួនចំណោទ)

### ប្រូក្រាមសម្រាប់ធ្វើការរុករកស្រាវជ្រាវ

«Grolier's Encyclopedia» K-12

long beach unified school district

ជូនចំពោះមាតាបិតា  អ្នកអាណាព្យាបាលសិស្ស

សូមស្វាគមន៏មកដល់ឆ្នាំសិក្សាថ្មី។  យើងសង្ឃឹមថានិងបន្តនូវជោគជ័យក្នុងការសិក្សាតទៅទៀតសម្រាប់សិស្សទាំងអស់នៅក្នុងក្រសួងសិក្សាធីការឡុងប៊ិច LBUSD ។

គោលបំណងនៃការបង្កើតកូនសៀវភៅពត៏មាននេះគឺដើម្បីធ្វើឲ្យលោកអ្នកស្គាល់ដឹងអំពីមុខវិជ្ជាសិក្សាសំខាន់ៗដែលកូនលោកអ្នកនិងបានទទួលនូវការបង្ហាត់បង្រៀននៅក្នុងឆ្នាំសិក្សានេះ ហើយនិងដើម្បីផ្ដល់ជាជំរុយដ៏មានប្រយោជន៏អំពីរបៀបដែលលោកអ្នកអាចជួយនៅផ្ទះហើយធ្វើឲ្យការសិក្សារបស់កូនមានខ្លឹមសារឡើង។  រាយខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែលបានមានបកស្រាយនៅក្នុងកូនសៀវភៅពត៏មាននេះ។

- គំរូនូវមុខវិជ្ជាសំខាន់ៗនៅក្នុងខ្នាតគំរូសិក្សារបស់រដ្ឋកាលីហ្វ័រនីញ៉ាទៅតាមកំរឹតថ្នាក់។
- សំនួរផ្សេងៗអំពីការយល់ដឹងសម្រាប់សួរកូនលោកអ្នកក្រោយពីកូនបានអានចប់នៅផ្ទះ។
- របៀបរៀនសូត្រឲ្យបានប្រសិទ្ធិភាពសម្រាប់ជួយកូនលោកអ្នកឲ្យបានទទួលជោគជ័យក្នុងការសិក្សា។
- ប្រូក្រាមកុំព្យូទ័រសម្រាប់ជួយឲ្យធ្វើការសិក្សាកាន់តែមានខ្លឹមសារឡើង។
- ទីកន្លែងសម្រាប់ទៅលេងជាមួយកូនដើម្បីធ្វើឲ្យកម្មវិធីសិក្សាតាមកំរឹតថ្នាក់របស់កូនឲ្យកាន់តែមានខ្លឹមសារឡើង។
- បញ្ជីអក្ខរានុក្រមនៃពាក្យប្រើក្នុងការសិក្សាដែលលោកអ្នកអាចឮពីកូនឬពីគ្រូបង្រៀនរបស់កូនលោកអ្នកក្នុងឆ្នាំសិក្សានិមួយៗ។
- សេចក្ដីសង្ខេបនៃច្បាប់វិន័យអំពីកិច្ចការគ្រូដាក់ឲ្យធ្វើនៅផ្ទះ (ហូមវើក) របស់ក្រសួងសិក្សាធិការឡុងប៊ិច LBUSD ។
- បញ្ជីឈ្មោះសៀវភៅអានសម្រាប់កម្រឹតថ្នាក់និមួយៗ។

ក្នុងនាមនៃគ្រូបង្រៀនឯកទេសដ៏យកចិត្តទុកដាក់  យើងមានសេចក្ដីពេញចិត្តនឹងនិងផ្ដល់ជូនលោកអ្នកនូវកូនសៀវភៅពត៏មាននេះដើម្បីជាគ្រឿងប្រដាប់សម្រាប់ជួយកូនលោកអ្នកឆ្ពោះទៅកាន់ជោគជ័យក្នុងការសិក្សាទៅដល់អនាគតកាល។

ដោយសេចក្ដីស្មោះចំពោះ

Christopher Steinhauser

*កំណត់សំគាល់: ខ្នាតគំរូមុខវិជ្ជាសិក្សាទាំងអស់ដែលមានរាយនៅក្នុងកូនសៀវភៅនេះបានសរសេរសម្រួលឡើងវិញពីឯកសារខ្នាតគំរូរបស់ក្រសួងសិក្សាធិការរដ្ឋកាលីហ្វ័រនីញ៉ាដើម្បីសម្រួលឲ្យមាតាបិតានិងអ្នកអាណាព្យាបាលសិស្សមានការយល់ដឹងជាទូទៅ ទៅលើកម្មវិធីសិក្សានៅតាមកំរិតថ្នាក់និមួយៗ។ សូមមើលទីបណ្តាញ Website របស់ក្រសួងអប់រំ [www.lbusd.k12.ca.us](http://www.lbusd.k12.ca.us) ដើម្បីឲ្យបានដឹងបញ្ជីគ្រប់ក្បោះក្បាយ។*

# ខ្នាតគំរូមុខវិជ្ជាសិក្សាផ្នែក ភាសាសាស្ត្រ

**1.0 ការធ្វើវិភាគពាក្យ ភាពចេះស្ទាត់ ហេយនងការលូតលាសនូវវាក្យស័ព្ទជាយថាក្រម**

* ស្គាល់ហើយប្រើចំណេះទំនងនៃការសរសេរ
* បកស្រាយពាក្យប្លែកមានព្យាង្គពីរ ហើយនិងពាក្យធម្មតាមានព្យាង្គច្រើន
* ស្គាល់អក្សរកាត់ទូទៅ (ឧ. Jan., Sun., Mr., St.)
* កត់សម្គាល់ហើយចេះប្រើត្រឹមត្រូវពាក្យពហុវចនៈធម្មតា (ឧ. -s, -es, -ies) និងពាក្យពហុវចនៈមិនធម្មតា (ឧ. fly/flies, wife/wives)
* យល់ហើយចេះពន្យល់ពាក្យ អវេវចនសព្ទ និង វេវចនសព្ទ ធម្មតា
* ស្គាល់ន័យរបស់ បុព្វបទ និង បច្ច័យ ធម្មតា (ឧ. over, un-, -ing, -ly)
* ចេះអានដាច់ហើយត្រូវឮសូរខ្លាំងៗ ហើយមានសម្លេងចុះឡើងនិងទឹកមុខសមរម្យ

**2.0 ការយល់ចេះទៅលើការអាន**

* ប្រើចំណងជើង មាតិការរឿង ហើយនិងចំណងជើងវគ្គសៀវភៅដើម្បីរកមើលពត៌មាននៅក្នុងសៀវភៅ
* ប្រើការចេះដឹងអំពីគោលបំណងរបស់អ្នកនិពន្ធដើម្បីយល់ដឹងពត៌មាននៅក្នុងសៀវភៅ
* និយាយឬបញ្ជាក់ឡើងវិញនូវព្រឹត្តិការណ៏ក្បោះក្បាយក្នុងសៀវភៅដើម្បីបញ្ជាក់នូវគោលគំនិត
* បកស្រាយពត៌មានពីឌីយ៉ាក្រាម ផែនទី និងគំនូរតាងក្រាហ្វិក
* សួរសំនួរបញ្ជាក់អំពីកត្តាសំខាន់ៗនៅក្នុងសៀវភៅ (ឧ. ហេតុអ្វី ប្រសិនជា របៀបណា)

**3.0 ការធ្វើវិភាគទៅលើអក្សរសាស្ត្រ**

* ប្រៀបធៀបឬបង្ហាញឲ្យឃើញភាពខុសគ្នា ទៅលើដំណើររឿង ឆាករឿង ហើយនិងតួឯករឿង សរសេរដោយអ្នកនិពន្ធផ្សេងៗ។
* បង្កើតជាផ្សេងនូវភាពបញ្ចប់នៃដំណើររឿង ហើយរកឃើញមូលហេតុ ហើយនិងឥទ្ធិពលនៃការផ្លាស់ប្តូរនេះ
* រកឃើញការប្រើប្រាសនៃចង្វាក់ ភាពចួនគ្នា ហើយនិង ចួនអក្សរដើមព្យាង្គ របស់កំណាព្យ

**1.0 ការសរសេរ**

* សិស្សចេះសរសេរឃ្លាច្បាស់ហើយទាក់ទងហូរហែ និងវគ្គដែលបណ្តុះនូវគោលគំនិតធំជាងគេ។ ចេះសរសេរដោយបង្ហាញថាគិតគូដល់អ្នកអានហើយនិងគោលបំណងនៃការសរសេរ។ សិស្សដុះលូតលាស់ទៅតាមដំណាក់នៃទម្រង់ការសរសេរ(ឧ. សរសេរព្រាង ពិនិត្យមើលសារឡើងវិញ កែសម្រួលជាដើម)
* យល់ពីគោលដៅនៃការប្រើប្រាសឯកសារយោង(ឧ. វចនានុក្រម កម្រងវេវចនៈសព្ទ ។ល។)

**2.0 ការដាក់អនុវត្តន៏នូវការចេះសរសេរ**

* សិស្សសរសេរតែងសេចក្តីដែលពណ៌នាហើយពន្យល់ពីវត្ថុ ព្រឹត្តិការណ៏ និងបទពិសោធន៏
* សរសេរជានិទានកថាខ្លីៗយោលទៅតាមបទពិសោធន៏ តាមលំដាប់លំដោយនៃព្រឹត្តិការណ៏ហើយពណ៌នាអំពីឆាកតួឯក និងព្រឹត្តិការណ៏យ៉ាងក្បោះក្បាយ
* សរសេរសំបុត្រមិត្តភាពមួយដែលមានថ្ងៃខែ ស្ថានការណ៏ តួសំបុត្រ ការបញ្ចប់ និងហត្ថលេខា

# សំនួរសម្រាប់សួរកូនលោកអ្នក ក្រោយពីកូនបានអានសៀវភៅរួចមក

## <u>សៀវភៅរឿងនិទានប្រឌិតឡើង</u>

- តើអ្នកណាជាអ្នកប្រាប់រឿងនេះ?
- តើរឿងនេះភាគច្រើនអំពីអ្វី?
- តើរឿងនេះនិងមានភាពផ្សេងរបៀបណាបើសិនជា__________ ?
- តើកូនគិតថាអ្នកនិពន្ធចង់ឲ្យយើងដឹងអ្វីខ្លះពីសៀវភៅនេះ?
- តើកូនគិតថានិងមានអ្វីកើតមានឡើងបន្ទាប់ទៅទៀត?

## <u>សៀវភៅតាមព្រឹត្តិការណ៏ពិត</u>

- តើទំព័រទី______ក្នុងសៀវភៅនេះអំពីអ្វី?
- ដើម្បីឲ្យបានដឹងថែមអំពី_________ តើសៀវភៅពង្រាងឯកសារមួយណាដែល__________?
- តើអ្វីបានបណ្តាល__________ ឲ្យ_____________ ?
- នៅក្នុងអត្ថបទ__________មានន័យថា_________________?

# ឈ្មោះសៀវភៅជាគំរូខ្លះៗ សម្រាប់ថ្នាក់ទី២

*រាយខាងក្រោមនេះគជាគំរូសៀវភៅនងអ្នកនពន្ធដល្អៗដែលលោកអ្នកនិងសប្បាយអានជាមួយកូនលោកអ្នកនៅផ្ទះ។ សម្រាប់ឈ្មោះសៀវភៅគំរូដ៏ល្អៗជាច្រើនទៀត សូមឆែក មើលនៅទីបណ្តាញ* ***Website*** *របស់ក្រសួងសិក្សាធិការ* ***LBUSD!***

- <u>Song and Dance Man</u> និពន្ធដោយ Karen Ackerman
- <u>Where the Forest Meets the Sea</u> និពន្ធដោយ Jeannie Baker
- <u>Big Al</u> និពន្ធដោយ Andrew Clements
- <u>Night Noises</u> និពន្ធដោយ Mem Fox
- <u>Amelia Bedelia (series)</u> និពន្ធដោយ Peggy Parish
- <u>Two Bad Ants</u> និពន្ធដោយ Chris Van Allsburg
- <u>Galimoto</u> និពន្ធដោយ Karen Lynn Williams

## ខ្នាតគំរូមុខវិជ្ជាផ្នែក វិទ្យាសាស្ត្រ

**វិទ្យាសាស្ត្ររូបនិយ**

សិស្សថ្នាក់ទី២និងរៀនដឹងថាចលនារបស់វត្ថុអាចធ្វើការសង្កេតមើលហើយនិងស្ទង់វាស់បាន។ នេះមានរួមទាំងការរៀនអំពីគ្រឿងប្រដាប់ហើយនិងម៉ាស៊ីនដែលប្រើសម្រាប់រុញនិងទាញដើម្បីធ្វើឲ្យវត្ថុកម្រើកមានចលនា។

**វិទ្យាសាស្ត្រអំពីជីវិត**

សិស្សថ្នាក់ទី២និងរៀនដឹងថារុក្ខជាតិនិងសត្វមានកំរឹតអាយុដែលយើងអានស្មានទុកបាន។ នេះមានរួមទាំងការដឹងថាដំណាក់ជាលំដាប់លំដោយក្នុងរង្វង់ជីវិត មានភាពខុសគ្នាពីសត្វមួយទៅសត្វមួយ ដូចជាមេអំបៅនិងកង្កែបជាដើម ហើយរៀនដឹងថាភាពតឹងតែងពិបាកនៅក្នុងបរិយាកាមានឥទ្ធិពលទៅលើពន្លកដុះឡើងនិងការលូតលាស់របស់រុក្ខជាតិ។

**វិទ្យាសាស្ត្រអំពីផែនដី**

សិស្សថ្នាក់ទី២និងរៀនដឹងថាផែនដីធ្វើមកអំពីវត្ថុធាតុដែលមានគុណភាពខុសគ្នា ហើយផ្តល់ជាធនធានដល់មនុស្ស។

**ការតាមដានស្រាវជ្រាវនិងការពិសោធន៏**

សិស្សថ្នាក់ទី២និងរៀនអំពីរបៀបវិធីវិទ្យាសាស្ត្រដោយសួរសំនួរមានប្រយោជន៏ហើយនិងធ្វើការតាមដានដោយប្រុងប្រយត្ន។ នេះអាចមានរួមទាំងការវាស់ប្រវែង ទម្ងន់ កម្តៅ ហើយនិងចំណុះទឹកជាមួយគ្រឿងប្រដាប់សមរម្យ ហើយផ្តល់លិទ្ធផលនៃការរង្វាស់នោះជាប្រពន្ធ័មាត្រាមេទ្រិក ហើយគូគំនូរតាងក្រាហ្វិកដើម្បីកត់ទុកនូវហេតុការណ៏។

## ខ្នាតគំរូមុខវិជ្ជាសិក្សាផ្នែក សិល្បៈគំនូរ្ចនា និងសិល្បៈសម្តែង

**រាំ ឬ របាំ** - បង្ហាញសមត្ថភាពក្នុងការប្រើចលនារួមផ្សំគ្នាផ្សេងៗ(ឧ. ដើរនិងរត់ ផាយនិងលោត ហក់និងរំលង រំអិលនិងរមៀល) ហើយនិងធ្វើចលនាអ័ក្ស (ឧ. យោលនិងទប់ជំហ៊ាទ្រង់ទ្រាយ បៃនិងពត់ អោននិងបង្វិល។

**តូរ្យតន្ត្រី** - ច្រៀងត្រូវតាមចង្វាក់ភ្លេងល្អតាមសម្លេងលូតលាស់សមរម្យ ច្រៀងចម្រៀងសមលម្មនិងអាយុដែលចងចាំ ហើយលេងគ្រឿងភ្លេងស្រួលៗនៅក្នុងថ្នាក់។

**ល្ខោន** -រកឃើញល្ខោននិងសណ្ឋាននៃការនិទានរឿងពីវប្បធម៏ផ្សេងៗ ហើយរកឃើញតួឯកទូទៅនៅក្នុងរឿងនិងល្ខោន ពីពេលវេលានិងទីកន្លែងផ្សេងៗពីគ្នា។

**សិល្បៈគំនូរ្ចនា** - ប្រៀបធៀបអធិបាយផ្សេងៗគ្នាទៅលើរូបសិល្បៈតែមួយ ហើយប្រើវេយ្យាករណ៏សិល្បៈដើម្បីនិយាយអំពីអ្វីខ្លះដែលគេចង់ធ្វើនៅក្នុងកិច្ចការផ្ទាល់ខ្លួនរបស់គេ ហើយនិងរបៀបដែលនិងធ្វើឲ្យមានជោគជ័យឡើង។

## ខ្នាតគំរូមុខវិជ្ជាសិក្សាផ្នែក សង្គមវិជ្ជា

**2.1** សិស្សធ្វើការប្រៀបធៀបនូវភាពខុសគ្នាអំពីហេតុការណ៏ដែលកើតឡើងយ៉ាងយូរមកហើយនិងហេតុការណ៏ដែលទើបតែកើតឡើង។

**2.2** សិស្សបង្ហាញចំណេះក្នុងការប្រើផែនទីដោយពណ៏នាទំនាក់ទំនងរបស់ទីកន្លែងនិងមនុស្សរស់នៅនិងបរិយាការ។

**2.3** សិស្សពន្យល់អំពីច្បាប់រដ្ឋាភិបាលហើយនិងកាអនុវត្តន៏នៅក្នុងសហរដ្ឋអាមេរិកហើយនិងប្រទេសដ៏ទៃទៀត។

**2.4** សិស្សយល់ដឹងអំពីគោលគំនិតសេដ្ឋកិច្ចជាគោលៗហើយនិងមុខងាររបស់មនុស្សម្នាក់ៗ ហើយបង្ហាញការយល់ដឹងទៅលើការគិតគូរពិចារណាអំពីសេដ្ឋកិច្ចជាទូទៅ។

**2.5** សិស្សយល់ពីសារៈសំខាន់នៃអំពើរនិងលក្ខណះរបស់មនុស្សម្នាក់ៗ ហើយពន្យល់ថា វីរជនតាំងពីរយូរយារមកហើយ ហើយនិងថ្មីៗ បានធ្វើឲ្យជីវិតមនុស្សដ៏ទៃប្រសើរឡើង(ឧ. ជីវប្រវត្តរបស់ Abraham Lincoln, Louis Pasteur, Sitting Bull, George Washington Carver, Marie Curie, Albert Einstein, Golda Meir, Jackie Robinson, Sally Ride) ។

## ខ្នាតគំរូមុខវិជ្ជាសិក្សាផ្នែក កាយវប្បកម្ម

**ការរៀនពីចលនា** សិស្សរៀនធ្វើកាយវិការឲ្យបានសក្តិសិទ្ធិមាំមួនល្អ។

**ការរៀនពីចលនា** សិស្សបង្ហាញការយល់ដឹងអំពីមូលដ្ឋាននៃចលនា។

**សីរវិទ្យាហាត់ប្រាណ** សិស្សមានសុខភាពល្អហើយរក្សាសុខភាពល្អនេះដើម្បីបង្កើនកំរឹតនៃភាពមាំមួននៃរាងកាយ។

**សីរវិទ្យាហាត់ប្រាណ** សិស្សបណ្តុះចំណេះ ការចេះដឹង និងចំណូលចិត្ត ដើម្បីរក្សានូវសកម្មភាពឲ្យសកម្មដើម្បីឲ្យមានសុខភាពល្អ។

**ការលូតលាស់និងអភិវឌ្ឍន៏របស់មនុស្ស** សិស្សបង្ហាញការយល់ដឹងនៃដំណាក់លូតលាស់ហើយនិងអភិវឌ្ឍន៏ហើយនិងផលរបស់វាទៅដល់ការធ្វើចលនាប្រើកម្លាំង។

**សីរវិទ្យា** សិស្សបង្ហាញការចេះដឹង ទទួល ហើយឲ្យតម្លៃទៅលើភាពខុសគ្នាហើយនិងសមត្ថភាពនិងសមិទ្ធិភាពរបស់សិស្សដ៏ទៃ។

**សោភ័ណភាព** សិស្សនិងបង្កើតការចេះលើកតម្លៃហើយនិងសោភ័ណភាពនៃចលនា ជាអ្នកសម្តែងឬជាអ្នកមើល។

**សង្គមវិជ្ជា** សិស្សបង្ហាញចរិយាសមរម្យក្នុងសង្គមដោយគោរពអ្នកដ៏ទៃ លើកតម្លៃដល់ភាពចម្រុះសាស្ត្រ ហើយទទួលស្គាល់សារៈសំខាន់នៃការយល់ដឹងអំពីវប្បធម៏ដ៏ទៃទៀត។

**ទស្សនះប្រវត្តិសស្ត្រ** សិស្សបង្ហាញការយល់ដឹងអំពីឥទ្ធិពលផ្សេងៗនៃវិវត្តន៏របស់សកម្មភាពដែលទាក់ទងនិងចលនា។

# របៀបរៀនសូត្រឱ្យបានប្រសិទ្ធិភាពសម្រាប់សិស្សថ្នាក់ទី២

- *បង្កើតទម្លាប់ទៀងទាត់សម្រាប់ដាក់ពេលវេលានិងទីកន្លែងធ្វើកិច្ចការគ្រូដាក់ឲ្យធ្វើ*
- *ផ្តល់ទីកន្លែងស្ងាត់ស្ងៀមហើយមានពន្លឺល្អសម្រាប់កូនរៀន*
- *លើកទឹកចិត្តឲ្យកូនអានសៀវភៅឬសរសេរសម្រាប់ជាការកំសាន្ត*
- *ផ្តល់សម្ភារៈសំអាងដូចជា វចនានុក្រម កម្រងវេវចនៈសព្ទ សព្ទវចនាធិប្បាយ ការប្រើអិនធើនែត (បណ្ណាល័យភាគច្រើនមានកុមព្យូទ័រដែលអាចប្រើអ៊ិនធើនែតបាន) សម្រាប់សិស្សដែលមានកាតបណ្ណាល័យហើយនិងគំនិតដែលចេះតែឆ្ងល់ហើយចង់ដឹង*
- *រំឮកកូនឲ្យសួរសំនួរអំពីសៀវភៅ នៅមុនពេល កំពុង និងក្រោយពេលដែលបានអាន*

## វិន័យស្តីពីហូមវើករបស់ក្រសួងអប់រំ

ជាសង្ខេប ក្រសួងសិក្សាធិការ LBUSD ជឿថា ហូមវើកជាចំណែកមួយដ៏សំខាន់ក្នុងកម្មវិធីសិក្សានៅក្នុងកំរិតថ្នាក់និមួយៗ។ ការដាក់ឲ្យធ្វើហូមវើកគឺមានគោលបំណងច្បាស់លាស់ដើម្បីទទួលផលប្រយោជន៏ដែលផ្តល់ឲ្យលោកអ្នកនូវគ្រឿងប្រដាប់ធ្វើទំនាក់ទំនងមួយដ៏សំខាន់អំពីការធ្វើបានសំរេចរបស់កូនលោកអ្នកទៅនិងខ្នាតគំរូមុខវិជ្ជាសិក្សា។ សូមមេត្តាជួយលើកទឹកចិត្តកូនលោកអ្នកឲ្យធ្វើហូមវើកដោយខ្លួនឯង ប៉ុន្តែសូមលៃពេលសំរាប់ណែនាំឬជួយកូននៅពេលកូនត្រូវការដើម្បីឲ្យកូនអាចបន្តធ្វើបានដោយខ្លួនឯងតទៅទៀត។ កំរិតថ្នាក់និមួយៗមានពេលវេលាកំណត់សំរាប់ធ្វើហូមវើកដែលសមរម្យទៅតាមសមត្ថភាពសិស្ស។ សិស្សថ្នាក់ទី២ត្រូវលៃពេលសំរាប់ធ្វើហូមវើកពី២០-៤០នាទីជារៀងរាល់ថ្ងៃ ឬ ១៦០នាទីជាសារុបក្នុងមួយអាទិត្យ។

## កន្លែងដំណើរកំសាន្តសិក្សាសម្រាប់កូនរៀនថ្នាក់ទី២របស់លោកអ្នក

សួនចិញ្ចឹមសត្វនៅអិលអេ **L.A. ZOO:(323)644-6400**

សារមន្ទីរសម្រាប់កុមារ: **(213) 687-8800**

ល្ខោន **International City: (562)436-4610**

មជ្ឈៈមណ្ឌធម្មជាតិ **Eldorado Nature Center: 570-1745**

អាងត្រី **Long Beach Aquarium of the Pacific 590-3100**

បណ្ណាល័យសាធារណៈ: **Cerritos Public Library 916-1350**

សារមន្ទីរកុមារ **Bowers Museum (KIDSEUM) 567-3695**

តមកពីខ្នាតគំរូមុខវិជ្ជាសិក្សាផ្នែកភាសាសាស្ត្រ:

**1.0 សន្ទតិកម្មនៃការសរសេរនិងការនិយាយភាសា**

សិស្សសរសេរហើយនិយាយដោយចេះស្ទាត់ដូចទៅតាមខ្នាតគំរូមុខវិជ្ជាសមរម្យទៅតាមកំរិតថ្នាក់(ឧ. ទ្រង់ទ្រាយឃ្លា វេយ្យករណ៏ វណ្ណយុត្ត សរសេរអក្សរធំនៅពីមុខឃ្លា និងសរសេរក្របក ល។ល)

**1.0 របៀបស្តាប់និងនិយាយ**

ស្តាប់ដោយប្រុងប្រយត្ននិ៍ហើយឆ្លើយតបទៅការនិយាយស្តី។ សិស្សនិយាយក្នុងលក្ខណៈមួយដែលណែនាំអ្នកស្តាប់ឲ្យយល់អំពីគោលគំនិតសំខាន់ៗ ដោយប្រើឃ្លានិងការលើកដាក់សម្លេងត្រឹមត្រូវ។

**2.0 ការប្រើប្រាសនូវរបៀបនិយាយស្តី (ប្រភេទហើយនិងលក្ខណៈ)**

សិស្សសូត្ររាយរាប់ខ្លីៗហើយនិយាយសម្តែងបង្ហាញអំពីបទពិសោធន៏ដែលធ្លាប់ស្គាល់ឬអំពីចំណូលចិត្ត (ឧ. និយាយពីគោលប្រធានអ្វីមួយដែលមានការពិតនិងក្បោះក្បាយ ដកស្រង់ពីប្រភពពត៌មានផ្សេងៗពីគ្នា)។

## ខ្នាតគំរូមុខវិជ្ជាសិក្សាផ្នែកគណិតសាស្ត្រ

**លេខ**

**1.0** រាប់ អាន និងសរសេរលេខទៅដល់១០០០ ហើយស្គាល់ខ្ទង់តម្លៃលេខនិមួយ។ ប្រៀបធ្មឹម ដាក់ឲ្យត្រូវក្រុមនូវលេខដល់១០០០ដោយប្រើរូបសញ្ញា តិចជាង ស្មើ ឬច្រើនជាង (<, =, >) ។

**2.0** ប៉ាន់ស្មាន គិតលេខ ហើយដោះស្រាយចំណោទដែលមានលេខបូកនិងសង លេខពីរឬបីខ្ទង់។

**3.0** ប្រើការបូកម្តងហើយម្តងទៀត រៀប ហើយនិងរាប់ដោយពហុគុណ ដើម្បីធ្វើលេខគុណ។ ប្រើការដកម្តងហើយម្តងទៀត ចែកឲ្យស្មើ ហើយរៀបបង្កើតក្រុមស្មើៗគ្នាជាមួយសលេខនៅសល់ដើម្បីធ្វើលេខចែក។ ដឹងក្បួនលេខមេលេខ ២ ៥ និង១០ ហើយសូត្រឲ្យចាំ។

**4.0** យល់ថាប្រភាគហើយនិងទសភាគអាចប្រើសម្រាប់តំណាងឈុតឬផ្នែករបស់លេខ។

**5.0** សិស្សបង្ហាញការដោះស្រាយចំណោទដោយបង្ហាញធ្វើជាតំណាង នូវការបូកនិងការដកចំនួនលុយ។

**6.0** ប្រើរបៀបប៉ាន់ស្មានក្នុងការគិតលេខនិងការដោះស្រាយចំណោទដែលមានប្រើលេខខ្ទង់មួយ ដប់ រយនិងពាន់។

**ពិជគណិត**

**1.0** ធ្វើលេខបូកនិងដកដោយប្រើហេតុការណ៏ពីផែនទី រូបគំនូតាង និងឃ្លាលេខ។

**រង្វាស់ហើយនិងរេខាគណិត**

**1.0** យល់ថាការវាស់វែងអាចធ្វើទៅបានដោយរកឃើញមាត្រារង្វាស់ វាស់មាត្រានោះម្តងហើយម្តងទៀត ហើយប្រៀបធៀបវាទៅនិងវត្ថុដែលត្រូវវាស់។

**2.0** ស្គាល់ហើយពណ៌នាកេតណភ័ណរបស់រូបរាងទូទៅ។ ពណ៌នាហើយដាក់តាមជំពូកនូវរុបរៀងរេខាគណិត(ឧ. រង្វង់ ត្រីកោណ បួនជ្រុង បួនជ្រុងទ្រវែង ស្វែរ សារជី បូសគីប) ព្រិស្មបួនជ្រុងទ្រវែង) ទៅតាមចំនួនរូបរាង មុខ ជាយ និងកំពស់។

**ស្ថិតិលេខ ការវិភាគ និង ភវនីយភាព**

**1.0** ប្រមូលហេតុការណ៏ហើយកត់ទុក រៀបចំ បង្ហាញ និងបកស្រាយហេតុការណ៏នៅលើរូបគំនូតាង។

**2.0** យល់អំពីទំនងហើយនិងការធំរីកនៃទំនងនេះ ហើយចេះពណ៌នា។

**ការគិតពិចារណាធ្វើលេខ**

**1.0** សម្រេចចិត្តអំពីរបៀបបង្កើតសំនួរចំណោទ(គិតរកវិធីនិងមធ្យោបាយហើយប្រើប្រដាប់រាប់ឬគំនូសដោះស្រាយ)

**2.0** ដោះស្រាយចំណោទហើយបង្ហាញនូវភាពសមហេតុសមផលនៃដំណោះស្រាយនេះ។

**3.0** កត់សម្គាល់ទំនាក់ទំនងរវៀងបញ្ហាចំណោទមួយទៅមួយ។